ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សភាផ្នែករដ្ឋប្បវេណី *******

សំណុំរឿងរដ្ឋប្បវេណី

លេខ ១២៤ **សាលដាស្រ្តដាក្រខ្មែរ**

ចុះថ្ងៃទី២៧ខែមេសាឆ្នាំ១៩៩៨ **តុលាការកំពូល**

សាលដីកា

លេខ : ១៣៧ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

ចុះថ្ងៃទី២៥ខែកក្កដាឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១_ | ឯកឧត្តម | ឌិត | មុន្ទី | ប្រធាន |
| ២_ | លោក | ប៉ែន | ស៊ុន | ចៅក្រម |
| ៣_ | លោក | ប្រាក់ | គឹមសាន | ចៅក្រម |
| ៤_ | លោក | ស៊ិន | ខឹម | ចៅក្រមរបាយការណ៍ |
| ៥_ | លោក | សោម | សិរីវឌ្ឍ | ចៅក្រម |

ក្រឡាបញ្ជី

លោក ទឹម សម្ភាវិទ្ធិ

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខនឹសាលដីកាលេខ៧២៤ ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤០៩ ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ វ៉ាយ ធឿន ភេទស្រី អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិឈូថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះ ឯម អឿម " ស " ម្តាយឈ្មោះ វ៉ាយ គ្រឹង " ស " ប្តីឈ្មោះ នេត អ៊ាល ។

មានមេធាវី អ្នកស្រី ស៊ិន ស៊ុងៃ

និងចុងបណ្តឹងសាទុក្ខឈ្មោះ នេត សំអាត ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិឈូថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះ នេត ណុប "ស" ម្តាយឈ្មោះ អ៊ំ យី " ស " ប្រពន្ធឈ្មោះ ខាត់ ខាត់ ។

និងតតិយជនឈ្មោះ ធូរ ធិន្ន ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅភូមិឈូថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងទាមទារដីលំនៅដ្ឋានទំហំ ៦ម × ១១៧ម.

បានឃើញបណ្តឹងសាទុក្ខលេខ៨៦១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី វ៉ាយ ឡឿន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេច នៃសាលដីកាលេខ ៧២៤ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១២៤ចុះថ្ងៃទី២៧ ខែមេសាឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៩_៨_៩៥ របស់ដើមចោទឈ្មោះ វ៉ាយ ឡឿន ប្តឹងសុំឱ្យឈ្មោះ នេត សំអាត ចែកដីទំហំ ៦ ,៥ម×១១៧ម មកឱ្យខ្លួនដោយសំអាងថា នៅឆ្នាំ១៩៨១ ពេលខ្លួនធ្វើមាតុភូមិនិវត្តន៍មករស់នៅជាមួយម្តាយក្មេកឈ្មោ អ៊ឹ យី និង ប្អូនថ្លៃឈ្មោះ នេត សំអាត ( ចុងចម្លើយ ) មុនពេលម្តាយក្មេកស្លាប់បានប្រាប់ថា ឱ្យចែកដីនេះ ( ដីកើតហេតុ ) ជាពីរចំណែក គឺឱ្យមកខ្លួនមួយចំណែក និង មួយចំណែកទៀតឱ្យទៅ នេត សំអាត ។ ក្រោយពេលបោះឆ្នោតហើយ ( ឆ្នាំ៩៣ ) ប្តីខ្លួនក៏ស្លាប់ ហើយនេត សំអាត បានធ្វើរបងព័ទ្ធយកដីនេះទាំងអស់ ។ មុនពេលមានទំនាស់នេត សំអាត បានបបួលខ្លួនលក់ដី ចែកគ្នាបានម្នាក់មួយតម្លឹងមាស តែខ្លួនមិនព្រមលក់ ។ ក្រោយមកឈ្មោះ អាត បានមកដេញខ្លួនឱ្យរុះផ្ទះចេញពីដីកើតហេតុ ហើយបើមិនរុះទេ ឱ្យមាសទៅគេប្រាំបីជីទៀត ។ ពេលដោះស្រាយនៅឃុំ ឈ្មោះ អាត បានយល់ព្រមប្រគល់ដីចំណែករបស់គាត់ មកឱ្យខ្លួនដោយឱ្យខ្លួនប្រគល់មាសប្រាំពីរជីបន្ថែមទៀត គិតបប់ប្រាំបីជី ដោយពីមុនមកឈ្មោះ អាត បានយកពីខ្លួនមួយជីហើយ ។ ដោយរកលុយមិនបានខ្លួនក៏ប្រាប់ឈ្មោះអាត ឱ្យលក់ដីចំណែករបស់ អាត ទៅ តែឈ្មោះអាត លក់ទាំងដីដែលជាចំណែករបស់ខ្លួនទៀតផង ទើបខ្លួនប្តឹងសុំសិទ្ធិគ្រប់គ្រងដីចំណែករបស់ខ្លួន គ្រប់គ្រងជាកម្មសិទ្ធិតទៅ ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៦_០១_១៩៩៦ របស់តតិយជនឈ្មោះនាង ហ៊ុន ពៅ ( ផ្ទេរសិទ្ធិឱ្យឈ្មោះ នូវ ធិន្ន ) ប្តឹងទាមទារដីលំនៅដ្ឋាន ( ដីកើតហេតុ ) និងសុំឱ្យនាងវ៉ាយ ឡឿន រុះផ្ទះចេញពីដីទំនាស់ដោយអាងហេតុថា ដីនេះខ្លួនបានទិញពីម្ចាស់ដើមឈ្មោះ នេត សំអាត ដោយមានលិខិតផ្ទេរសិទ្ធិ លក់ដី និងមានសាក្សីដឹងឮ ត្រឹមត្រូវទៀតផង ។

បានឃើញសាលក្រមលេខ ០៦ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការខេត្តតាកែវ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ០៩_៨_៩៥ របស់ដើមចោទឈ្មោះ វ៉ាយ ឡឿន ទុកជាត្រឹមត្រូវតាមទំរង់ តែសំរេចបដិសេធពាក្យបណ្តឹងនេះចោលដោយខុសនឹងគតិច្បាប់ ។

២_ ទទួលពាក្យបណ្តឹងតបតតិយជនចុងចម្លើយ ឈ្មោះហ៊ុន ពៅ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់។

៣_ ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៦_០១_៩៦ របស់តតិយជន ចុងចម្លើយឈ្មោះ ហ៊ុន ពៅ ឱ្យទៅតំណាងឈ្មោះ នូវ ធិន្ន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៤_ ទទួលស្គាល់លិខិតទិញ_លក់ ដីលំនៅដ្ឋាន ចុះថ្ងៃទី ៥_៩_៩៥ រវាងអ្នកលក់ឈ្មោះ នេត សំអាត និង ប្រពន្ធឈ្មោះ ខាត់ ខាន់ និង អ្នកទិញឈ្មោះ សំ ពៅ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៥_ ដីទំនាស់ដែលមាន ជ្រុងខាងជើង និងខាងត្បូងប្រវែង ៨៨ម. ជ្រុងខាងកើតប្រវែង ៦ ,៥០ម ជ្រុងខាងលិចប្រវែង ៦ ,៨០ម មានព្រំប្រទល់ខាងជើងទល់ដី ណុប សែន ខាងត្បូងទល់ដីឈ្មោះ ហ៊ុន ពៅ ខាងកើតទល់ចំណីផ្លូវជាតិលេខ ២ ខាងលិចទល់ដីឈ្មោះ ណុប សែន ដែលស្ថិតនៅក្នុងភូមិល្វថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង

ខេត្តតាកែវ ។ ត្រូវប្រគល់សិទ្ធិឱ្យគតិយជនចុងចម្លើយឈ្មោះ ហ៊ុន ពៅ តំណាងដោយឈ្មោះ នូវ ធិន្ន កាន់កាប់និងប្រើប្រាស់តាមច្បាប់តទៅ ។

៦_ បង្គាប់ឱ្យដើមចោទឈ្មោះ វ៉ាយ ឡឿន រុះរើលំនៅឋានចេញពីដីទំនាស់ ក្នុងកំណត់រយៈពេល៣០ថ្ងៃ គិតចាប់តាំងពីថ្ងៃផុតបណ្តឹងឧទ្ធរណ៍ ។

៧_ សំណើរបស់សងប្រាក់ប្រដាប់ក្តីគឺ : ពន្ធហ្គ៊ីង និង ពន្ធចុះបញ្ជីក្តី ១៨០០៛០០ រង្វាន់ក្រឡាបញ្ជីហិបប្រាក់ចំនួន ២០០៛០០ ចំណាយលើការប្រគល់ដីកាកោះចំនួន៥០០០៛០០ សរុប ៧០០០៛០០ ពីដើមចោទឈ្មោះ វ៉ាយ ឡឿន ដែលបានបង់ទុករួច ។

កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់ឱ្យដើមចោទឈ្មោះ នាង វ៉ាយ ឡឿន បង់ពន្ធសមាមាត្រមួយភាគរយលើតំលៃដីដែលមានទំនាស់គឺ : $\frac{៦៧៥.០០០ \times ១}{១០០}$ = ៦.៧៥០៛០០ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយគឺ : $\frac{៦៧៥០ \times ៨០}{១០០}$ = ៥.៤០០៛០០ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយគឺ : $\frac{៦៧៥០ \times ២០}{១០០}$ = ១៣៥០៛០០ ។

សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍កំណត់រយៈពេល៦០ថ្ងៃ គិតចាប់តាំងពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១០ ចុះថ្ងៃទី ០៥ ខែមិនា ឆ្នាំ១៩៩៧ របស់អ្នកស្រី វ៉ាយ ឡឿន ដែលប្តឹងជំទាស់នឹងសាលក្រមលេខ០៦ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការខេត្តតាកែវ លើសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧២៤ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៥_៣_៩៧ របស់ឈ្មោះ វ៉ាយ ឡឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ ដំកល់សាលក្រមរដ្ឋប្បវេណីលេខ ០៦ ចុះថ្ងៃទី ២០_០២_៩៧ របស់តុលាការខេត្តតាកែវ ទុកជាបានការដដែល ។

៣_ កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្គ៊ីង ២៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛០០ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛០០ និងអាជ្ញាធរតុលាការ ៥.០០០៛០០ សរុប ១៣០០០៛០០ ។

៤_ សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤៦១ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី វ៉ាយ ឡឿន

បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៧២៤ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី ០៤-៨-១៩៩៩ របស់អ្នកស្រី វ៉ាយ ធឿន

បានឃើញសារណាតប ចុះថ្ងៃទី ២៤-០១-២០០០ របស់លោក នេត សំអាត

បានឃើញសារណាតប ចុះថ្ងៃទី ២៤-០១-២០០០ របស់លោក នូវ និន្ន " តតិយជន "

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

- បណ្តឹងសាទុក្ខរបស់ដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ៧២៤ ចុះថ្ងៃទី ០២-១២-៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ និងគតិច្បាស់ហើយ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ វ៉ាយ ធឿន ជាដើមចោទ និង ម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ក្នុងឆ្នាំ១៩៨១ ខ្ញុំ ព្រមទាំងក្រុមគ្រួសារ បានធ្វើមាតុភូមិនិវត្តន៍មកកាន់ស្រុកកំណើតវិញ ដោយបានទៅរស់នៅជាមួយម្តាយក្មេកឈ្មោះ អ៊ំ យី កាលណោះ នៅទូទាំងប្រទេសរដ្ឋាភិបាលបានចេញគោលនយោបាយបែងចែកដីធ្លីជូនប្រជាជនមាតុភូមិនិវត្តន៍ ក្នុងនោះក៏មានគ្រួសារខ្ញុំមួយដែរ ។ តែម្តាយខ្ញុំ ពុំឱ្យគ្រួសារខ្ញុំចេញទៅណាទេ គាត់សុខចិត្តបែងចែកដីជាកម្មសិទ្ធិរបស់គាត់ ១ចំហៀង ឱ្យខ្ញុំធ្វើផ្ទះនៅ និងទុកមួយចំហៀងសំរាប់គាត់រស់នៅជាមួយកូនឈ្មោះ នេត សំអាត ដែលស្ថិតនៅក្នុងបន្ទុករបស់គាត់ ។ នៅឆ្នាំ ១៩៩២ ម្តាយខ្ញុំឈឺស្លាប់ ហើយឆ្នាំ ១៩៩៣ ប្តីខ្ញុំក៏ស្លាប់ទៀតបានបន្សល់ទុកកូន ៥នាក់ នៅក្នុងបន្ទុក ។ រំលងបាន ២ ,៣ ឆ្នាំក្រោយមកឈ្មោះ នេត សំអាត ជាប្អូនថ្លៃ បានបបួលខ្ញុំលក់ដីទាំងអស់នេះចេញ តែដោយខ្ញុំមិនព្រមលក់គេក៏លក់ដីជាចំណែករបស់គេមកឱ្យខ្ញុំចំនួន ៨ជី ដោយពុំទាន់មានប្រាក់ឱ្យខ្ញុំក៏ប្រគល់ជូន ១ជីសិន ចាំរុះរើផ្ទះហើយចាំឱ្យ ៧ជីទៀត តែក្រោយមកឈ្មោះ នេត សំអាត ប្រែក្រឡាស់ពុំព្រមលក់មកឱ្យខ្ញុំវិញទេ ហើយថែមទាំងលួចលក់ដីជាចំណែករបស់ខ្ញុំទៀត ។ សូមសំណូមពរទាមទារដីចំណែករបស់ខ្ញុំវិញ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ នេត សំអាត ជាចុងចម្លើយ និងចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ការលើកឡើងរបស់បងស្រីឈ្មោះ វ៉ាយ ធឿន ដែលបានលើកឡើងនេះ គឺបង្កាច់បង្ខូចទាំងស្រុង ដីនេះខ្ញុំបានកាន់កាប់តាំងពីឆ្នាំ ១៩៧៩ កាលណោះម្តាយខ្ញុំចាស់ជរាស្ថិតនៅក្នុងបន្ទុករបស់ខ្ញុំ ឯបងខ្ញុំទើបតែមករស់នៅក្នុងឆ្នាំ ១៩៨៣ ទេ ខ្ញុំពិតជាបានលក់ដី១ចំហៀងឱ្យទៅបងឈ្មោះ វ៉ាយ ធឿន ក្នុងតំលៃ ៨ជី ពិតមែន ដោយកក់ចំនួន ១ជី តែដោយគាត់គ្មានប្រាក់ឱ្យគ្រប់ ខ្ញុំក៏លក់ដីនេះទៅឱ្យអ្នកផ្សេងវិញ ។ ខ្ញុំសូមបញ្ជាក់ថាដីនេះ គឺខ្ញុំបានកាន់កាប់ពីឆ្នាំ ១៩៧៩ ប្រាកដមែន ដោយមានរដ្ឋអំណាចទទួលស្គាល់ត្រឹមត្រូវ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ នូវ និន្ន ជាតតិយជន នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : សូមបដិសេធរបាយការណ៍របស់ដើមចោទទាំងស្រុងឈ្មោះ នេត សំអាត បានកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៧៩ ដោយមានម្តាយចាស់ជរានៅក្នុងបន្ទុក ដោយឡែកបងរបស់នេត សំអាត ទើបធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើត ក៏ទិញដីពីនេត សំអាត ក្នុងតំលៃ ៨ជីមាស តែទើបតែឱ្យ ១ជី ប៉ុណ្ណោះ ហើយក៏ធ្វើផ្ទះនៅរហូតមក ដោយមានទំហំ

៦ម × ១១៧ម ។ ខ្ញុំបាទសូមជំរាប ឯកឧត្តមថា ក្នុងឆ្នាំ១៩៨១ នេត សំអាត មានកូន ២នាក់ រួចទៅហើយ ហើយបច្ចុប្បន្នមានដល់ ៧នាក់ ឯណោះ ។ ពេលទិញដីនេះ ខ្លួនដឹងថាមានទំនាស់រួចទៅហើយ ក៏ប៉ុន្តែដោយអាងថា ដីនោះជារបស់ នេត សំអាត ព្រោះខ្លួនក៏ជាអ្នករស់នៅភូមិនេះ តាំងពីឆ្នាំ ១៩៧៩ មកដែរ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីអ្នកស្រី ស៊ុន ស៊ីវិន បញ្ជាក់ថា: ដីទំនាស់នេះ គឺជាដីកម្មសិទ្ធិរបស់ឈ្មោះ អ៊ំ យី ដែលជាម្តាយ បានគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩មកម្លេះ ដោយគាត់ជាមេគ្រួសារ ។ ឆ្នាំ ១៩៨១ វ៉ាយ ឡឿន និង ក្រុមគ្រួសារ បានធ្វើមាតុភូមិនិវត្តន៍ត្រឡប់មករស់នៅស្រុកកំណើតវិញ ម្តាយឈ្មោះ អ៊ំ យី បានចែកដីឱ្យ ១ចំហៀង ឯ១ចំហៀងទៀត សំរាប់រស់នៅជាមួយកូនឈ្មោះ នេត សំអាត ។ ក្រោយពេលម្តាយឈ្មោះ អ៊ំ យី ស្លាប់ ឈ្មោះ នេត សំអាត ក៏ចាប់ផ្តើមរំលោភបំពានលួចយកដីរបស់ វ៉ាយ ឡឿន ទៅលក់ ដែលជាការបំពាន និងអំពើរបស់ម្តាយខ្លួន ។ តាមការស្រាវជ្រាវឃើញថា ដីនេះជាកម្មសិទ្ធិរបស់ឈ្មោះ អ៊ំ យី ពិតប្រាកដណាស់ ព្រោះឆ្នាំ ១៩៧៩ ឈ្មោះ នេត សំអាត នៅជាអនិតិជននៅឡើយ យោងតាមច្បាប់ភូមិបាលមាត្រា ១៧០ ចែងថា : សន្តតិកម្ម គឺជាការផ្ទេរទ្រព្យបេតិកភ័ណ្ឌ នៃបុគ្គលណាម្នាក់ឱ្យទៅជនម្នាក់ទៀត ឬ ច្រើនអ្នកហៅថាទាយាទ ។ ក្នុងនាមមេធាវីការពារក្តី នាងខ្ញុំសូមសំណូមពរ សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី របស់គណិយជន និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៦១ ចុះថ្ងៃទី ០២_១២_៩៧ របស់អ្នកស្រី វ៉ាយ ឡឿន ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចតុលាការខេត្តតាកែវ ដែលយល់ឃើញថា លោក នេត សំអាត បានកាន់កាប់ដីទំនាស់តាំងពីឆ្នាំ១៩៧៩ ដោយអាងហេតុថា អ្នកស្រី អ៊ំ យី ជាម្តាយរស់នៅក្នុងបន្ទុករបស់លោក នេត សំអាត នោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា តាមបញ្ជីគ្រួសារលេខ៣៥៨ សៀវភៅលេខ IV ចុះថ្ងៃទី ១១_១១_៨៦ លោក នេត សំអាត កើតនៅឆ្នាំ ១៩៧០ ដូច្នេះលោក នេត សំអាត មានអាយុទើបតែ ០៩ឆ្នាំ ដែលពុំអាចមានសិទ្ធិទទួលរបបដីធ្លីបានឡើយ ។

- យល់ឃើញថា ក្នុងកំណត់ហេតុដោះស្រាយទំនាស់ ចុះថ្ងៃទិ ១៩_១០_៩៤ ( ឯ.១៣៦ ) របស់សាលាឃុំ ៨មុំ ក៏ដូចកំណត់ហេតុផ្សះផ្សា ចុះថ្ងៃទី ១២_៨_៩៥ របស់តុលាការខេត្តតាកែវដែរ ចុងចម្លើយសុទ្ធតែទទួលស្គាល់ថា ដីទំនាស់ត្រូវម្តាយខ្លួនចែកឱ្យដើមចោទរួចហើយ ។

- យល់ឃើញថា ចុងចម្លើយយកដីបណ្តាំសន្តតិកម្មផ្ទះរបស់ម្តាយទៅលក់ឱ្យជនដទៃ ជាការបំពាននឹង

មាត្រា ១៧០ នៃច្បាប់ភូមិបាល ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧២៤ ចុះថ្ងៃទី ០២-១២-៩៧ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខក្តី**

១- ទទួលបណ្តឹងសាទុក្ខលេខ ៥៦១ ចុះថ្ងៃទី ០២-១២-៩៧ របស់អ្នកស្រី វ៉ាយ ឡើន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ៧២៤ ចុះថ្ងៃទី ០២-១២-៩៧ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី ២៧-៤-៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី ដែលដើមចោទបានបង់ទុកនៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធឃ្លឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតំរូវឱ្យចុងចម្លើយសងប្រាក់ចំនួន ១៩.០០០រៀល នេះ ទៅឱ្យដើមចោទវិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ។